**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

-សំណុំរឿងរដ្ឋប្បវេណីលេខ: ២៨៦
ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៩
-សាលក្រមលេខ: ៣៥ "ច"
ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

# តា ង នា ម ប្រ ជា រា ស្ត្រ ខ្មែ រ

## សាលាដំបូងខេត្តសៀមរាប

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង៩.៣០នាទីព្រឹក នៃសាលាដំបូងខេត្តសៀមរាប។

-បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០។

-កាលបរិច្ឆេទប្រកាសសាលក្រម នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង២.៣០នាទីរសៀល។

### ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លើសំណុំរឿងរដ្ឋប្បវេណីលេខ: ២៨៦ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៩ ដែលមាន៖

**សហដើមចោទ៖**

-ឈ្មោះ [redacted] អាត ភេទប្រុស កើតឆ្នាំ១៩៧៩ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]

-ឈ្មោះ [redacted] សុទ្ធា ភេទស្រី កើតឆ្នាំ១៩៧៧ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]

-ឈ្មោះ [redacted] អោក ភេទប្រុស កើតឆ្នាំ១៩៧៤ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]

-ឈ្មោះ [redacted] អំ ភេទប្រុស កើតឆ្នាំ១៩៨០ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ[redacted]

-ឈ្មោះ [redacted] អ៊ុច ភេទប្រុស កើតឆ្នាំ១៩៨១ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ[redacted]



Scanned with CamScanner

-ឈ្មោះ [redacted] សុទ្ធិន ភេទស្រី កើតឆ្នាំ១៩៨៥ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិ [redacted]។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិសហាដើមចោទ មានការិយាល័យ [redacted]។

**សហាចុងចម្លើយ៖**

-ឈ្មោះ [redacted] **សុធារី** (អ៊ុល សុធារី) ភេទស្រី កើតឆ្នាំ១៩៨៣ ជាតិខ្មែរ ទីលំនៅ [redacted]។

-ឈ្មោះ [redacted] **សំអាង** (អ៊ុល សំអាង) ភេទប្រុស កើតឆ្នាំ១៩៨៩ ជាតិខ្មែរ ទីលំនៅ [redacted]។

-ឈ្មោះ [redacted] **សុភា** [redacted] សុភា) ភេទប្រុស កើតឆ្នាំ១៩៨៧ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted]។

-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិចុងចម្លើយឈ្មោះ [redacted] **សុធារី** មានការិយាល័យនៅផ្ទះលេខ ៦D5,ការិយាល័យមេធាវី [redacted]។

## អង្គហេតុនិងចំនុចវិវាទ

### ១-ខ្លឹមសារនៃសាលក្រមដែលទាមទារដោយសហាដើមចោទ

ក-មិនអនុញ្ញាតអនុវត្តដីកាសម្រេចលេខ: ១២១ ពស.រវ"ក"/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប ។

ខ-លុបចោលការអនុវត្តតាមកំណត់ហេតុអនុវត្ត ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ អាជ្ញាសាលានៃសាលាដំបូងខេត្តសៀមរាប ត្រង់ចំណុច១ ដែលមានខ្លឹមសារថា "ភាគីម្ចាស់បំណុលនៃការអនុវត្តមានឈ្មោះ [redacted] សុធារី,ឈ្មោះ [redacted] សំអាង និងឈ្មោះ [redacted] សុភា សម្រេចយកចំណែកA ដូចក្នុងប្លង់ដែលត្រូវគូសខាងក្រោម៖

គ-ទទួលស្គាល់សហាដើមចោទ និងសហាចុងចម្លើយ ជាសន្តិជនរបស់មរតកជនឈ្មោះ អ៊ូន អុល (អ៊ួន អុល)។

ឃ-បែងចែកមត៌ក ដីទំហំ១៦,៦៥ម គុណ ៤៨ម ដែលស្ថិតនៅផ្នែកខាងនៃក្បាលដីលេខ: ១៦៥៥ មានព្រំប្រទល់ ខាងជើងទល់នឹងក្បាលដីលេខ: ១៦៥៥, ខាងត្បូងទល់នឹងក្បាលដីលេខ ១៧០៦ ខាងកើតទល់នឹងក្បាលដីលេខ ១៥៧១ និងខាងលិចទល់នឹងផ្លូវបេតុង មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប របស់មតកជនឈ្មោះ [redacted] អុល [redacted] អុល) ឲ្យសន្តតិជនជា ៩ ចំណែកស្មើគ្នា មានឈ្មោះ [redacted] អាត,ឈ្មោះ [redacted] សុទ្ធា,ឈ្មោះ [redacted] អេក,ឈ្មោះ [redacted] អំ,ឈ្មោះ [redacted]



Scanned with CamScanner

អ៊ិច,ឈ្មោះ [redacted] សុទ្ធិន,ឈ្មោះ [redacted] សុធារី([redacted] សុធារី), ឈ្មោះ [redacted] សំអាង [redacted] សំអាង) និងឈ្មោះ [redacted] សុភា ([redacted] សុភា) ដោយនៅក្នុងនីតិវិធីត្រៀមលើកទី២ មេធាវីតំណាងដោយអាណត្តិសហដើមចោទសុំប្តូរមកបែងចែកដីទំហំមតិក១១,២២ម គុណ ៤៨ម វិញ។

ង-ឲ្យសហដើមចោទ និងសហចុងចម្លើយរួមគ្នាទទួលប្រាក់ប្រដាប់ក្តីជាបន្ទុក។

## ២-អង្គហេតុ(ការពន្យល់ត្រួសៗអំពីរឿងក្តី)

សហដើមចោទទាំង៦នាក់ មានឪពុកបង្កើតម្នាក់ឈ្មោះ [redacted] អុល [redacted] អុល) ជាបុរសពោះម៉ាយបានយកស្ត្រីមេម៉ាយឈ្មោះ [redacted] សុខហួរ ([redacted] សុខហួ) ដែលមានកូន ៣នាក់ មានឈ្មោះ [redacted] លក្ខិណា [redacted] សុផារី, និងឈ្មោះ [redacted] សុខញ៉ ([redacted] វិជ្ជា) ធ្វើជាប្រពន្ធ។ ឈ្មោះ [redacted] អុល([redacted] អុល) និងឈ្មោះ [redacted] សុខហួ ([redacted] សុខហួ) ក្រោយពីបានគ្នាជាប្តីប្រពន្ធមកគឺមាន៣នាក់ទៀត គឺមានឈ្មោះ ១.ឈ្មោះ [redacted] សុធារី ([redacted] សុធារី) ភេទស្រី កើតឆ្នាំ១៩៨៣ ២.ឈ្មោះ [redacted] សំអាង ([redacted] សំអាង) ភេទប្រុស កើតឆ្នាំ១៩៨៥ និង៣.ឈ្មោះ [redacted] សុភា([redacted] សុភា) ភេទប្រុស កើតឆ្នាំ១៩៨៧ និងមានទ្រព្យរួម ដីមួយកន្លែងទំហំ២២,២២ម គុណ៤៨ម មានក្បាលដីលេខ ១៧០៦ ខាងកើតទល់នឹងក្បាលដីលេខ ១៥៧១ និងខាងលិចទល់នឹងផ្លូវបេតុង មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ឈ្មោះ [redacted] អ៊ុល [redacted] អុល) បានទទួលមរណៈភាពកាលពីក្នុងឆ្នាំ១៩៩០ មានសំបុត្រមរណៈភាពលេខ ១០០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ (ដូចមានការបញ្ជាក់នៅក្នុងកំណត់ហេតុស្តីពីការសាកសួរ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប) និងឈ្មោះ [redacted] សុខហួរ ([redacted] សុខហួ) បានទទួលមរណៈភាព កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ (លិខិតបញ្ជាក់មរណៈភាពលេខ ៥១៦ ប.ជ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ របស់មេឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ)។ ក្រោយពីឈ្មោះ [redacted] អុល ([redacted] អុល) និងប្រពន្ធឈ្មោះ [redacted] សុខហួរ([redacted] សុខហួ) ទទួលមរណៈភាពទៅបានបន្សល់នូវមរតករួម គឺដីមួយកន្លែងទំហំ២២,២២ម គុណ ៤៨ម មានក្បាលដីលេខ ១៦៥៥ ដែលមានព្រំប្រទល់ខាងជើងទល់នឹងក្បាលដីលេខ ១៦៥៤ ខាងត្បូងទល់និងក្បាលដីលេខ ១៧០៦ ខាងកើតទល់និងក្បាលដីលេខ១៥៧១ និងខាងលិចទល់និងផ្លូវបេតុង។មរតករួមនេះគឺមានចំណែករបស់មរតកជនឈ្មោះ [redacted] អុល ([redacted] អុល) ៥០% និងឈ្មោះ [redacted] សុខហួរ ([redacted] សុខហួ)៥០%។

ក/.កន្លងមកចំណែក៥០% របស់មរតកជនឈ្មោះ [redacted] សុខហួរ [redacted] សុខហួ) ត្រូវបានសន្តតិជន(កូនមុន)មានឈ្មោះ [redacted] លក្ខិណា, [redacted] សុផារី និងឈ្មោះ [redacted] សុខញ៉([redacted] វិជ្ជា)បានធ្វើការបែងចែកជាមួយសន្តតិជន(កូនក្រោយសហចុងចម្លើយ)ឈ្មោះ

[redacted] សុធារី([redacted] សុធារី),ឈ្មោះ [redacted] សំអាង([redacted] សំអាង)និងឈ្មោះ [redacted] សុភា [redacted] សុភា)រួចហើយ តាមដីកាសម្រេចលេខ១២១ ពស.រវ "ក"/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប ដែលបានបែងចែកនេះគឺះ

កូនមុន មានឈ្មោះ [redacted]លក្ខិណា,[redacted]សុជាវី និងឈ្មោះ [redacted] សុខញ៉ [redacted] វិជ្ជរា)ទទួលបាន៥០% នៃចំណែកមរតករបស់ឈ្មោះ [redacted] សុខហួរ ([redacted]សុខហួ)គឺស្មើ ២៥%នៃចំណែកមរតករួម ហើយទទួលបានចំណែកដីស្មើនិងទំហំ ៥,៥មX៤៨ម ផ្នែក ខាងជើង។

កូនក្រោយ (សហចុងចម្លើយ)មានឈ្មោះ [redacted] សុធារី([redacted] សុធារី),ឈ្មោះ[redacted] សំអាង([redacted] សំអាង) និងឈ្មោះ [redacted] សុភា([redacted] សុភា)ទទួលបាន៥០% នៃចំណែក មរតករបស់ឈ្មោះ [redacted]សុខហួរ([redacted] សុខហួ)គឺស្មើ២៥% នៃចំណែកមរតករួម ទទួល បានចំណែកដីស្មើនិងទំហំ៥,៥មX៤៨ម ផ្នែកខាងត្បូង។

ដោយឡែកចំណែកមរតករបស់មរតកជន ឈ្មោះ [redacted] អុល ([redacted] អុល)ចំនួន ៥០% នៃដីខាងលើនៅផ្នែកខាងត្បូង ដែលមានចំណែករបស់សន្តតិជន៩នាក់មានះ

កូនមុន ជាសហដើមចោទ ៦នាក់មាន ឈ្មោះ [redacted] អាត [redacted] សុទ្ធា,[redacted] អោក [redacted] អំ,[redacted] អ៊ុច,ឈ្មោះ [redacted] សុទ្ធិន។

កូនក្រោយ ជាសហចុងចម្លើយ ៣នាក់មានឈ្មោះ [redacted]សុធារី([redacted] សុធារី), [redacted]សំអាង([redacted] សំអាង) និងឈ្មោះ [redacted] សុភា[redacted]សុភា)។ នៅមិនទាន់បានធ្វើការបែងចែកនៅឡើយ។

**៣-សេចក្តីថ្លែងការណ៍របស់គូភាគី**

**សេចក្តីថ្លែងការណ៍មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទះ** សហដើម ចោទទាំង៦នាក់ មានឪពុកបង្កើតម្នាក់ឈ្មោះ [redacted] អុល [redacted] អុល) ជាបុរសពោះម៉ាយ បានយកស្ត្រីមេម៉ាយឈ្មោះ [redacted] សុខហួរ ([redacted] សុខហួ) ដែលមានកូន៣នាក់ មាន ឈ្មោះ [redacted] លក្ខិណា,[redacted] សុជាវី, និងឈ្មោះ [redacted] សុខញ៉ ([redacted] វិជ្ជរា) ធ្វើជាប្រពន្ធ។ ឈ្មោះ [redacted] អុល [redacted] អុល) និងឈ្មោះ [redacted] សុខហួ ([redacted] សុខហួ) ក្រោយពីបានគ្នាជាប្តី ប្រពន្ធមកគឺមានកូន៣នាក់ទៀត គឺមានឈ្មោះ ១.ឈ្មោះ [redacted] សុធារី ([redacted] សុធារី) ភេទស្រី កើតឆ្នាំ១៩៨៣ ២.ឈ្មោះ [redacted] សំអាង [redacted] សំអាង) ភេទប្រុស កើតឆ្នាំ ១៩៨៩ និង៣.ឈ្មោះ [redacted] សុភា([redacted] សុភា) ភេទប្រុស កើតឆ្នាំ១៩៨៧ និងមានទ្រព្យ រួម ដីមួយកន្លែងទំហំ២២,២២ម គុណ៤៨ម មានក្បាលដីលេខ ១៧០៦ ខាងកើតទល់ នឹងក្បាលដីលេខ ១៥៧១ និងខាងលិចទល់នឹងផ្លូវបេតុង មានទីតាំងស្ថិតនៅភូមិចុង កៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប។ឈ្មោះ [redacted] អុល ([redacted] អុល) បានទទួលមរណៈភាពកាលពីក្នុងឆ្នាំ១៩៩០ មានសំបុត្រមរណៈភាពលេខ ១០០ ចុះថ្ងៃ ទី០៨ ខែតុលា ឆ្នាំ២០១២ (សំបុត្រមរណៈភាពនេះនឹងសហកូនបំណុល ដូចមានការ

បញ្ជាក់នៅក្នុងកំណត់ហេតុស្តីពីការសាកសួរ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៨ របស់សាលាដំបូងខេត្តសៀមរាប) និងឈ្មោះ [redacted] សុខហូរ [redacted] សុខហូ) បានទទួលមរណៈភាព កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១២ (លិខិតបញ្ជាក់មរណៈភាពលេខ ៥១៦ ប.ជ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៧ របស់មេឃុំត្បូងក្រពើ ស្រុកសន្ទុក ខេត្តកំពង់ធំ)។ ក្រោយពីឈ្មោះ [redacted] អុល [redacted] អុល) និងប្រពន្ធឈ្មោះ [redacted] សុខហូរ( [redacted] សុខហូ) ទទួលមរណៈភាពទៅបានបន្សល់នូវមតិករួម គឺដីមួយកន្លែងទំហំ២២,២២ម គុណ ៤៨ម មានក្បាលដីលេខ ១៦៥៥ ដែលមានព្រំប្រទល់ខាងជើងទល់នឹងក្បាលដីលេខ ១៦៥៤ ខាងត្បូងទល់និងក្បាលដីលេខ ១៧០៦ ខាងកើតទល់និងក្បាលដីលេខ ១៥៧១ និងខាងលិចទល់និងផ្លូវបេតុង។បតិករួមនេះគឺមានចំណែករបស់មតកជនឈ្មោះ [redacted] អុល [redacted] អុល) ៥០% និងឈ្មោះ [redacted] សុខហូរ [redacted] សុខហូ)៥០%។

កន្លងមកចំណែក៥០% របស់មតកជនឈ្មោះ [redacted] សុខហូរ [redacted] សុខហូ)ត្រូវបានសន្តតិជន(កូនមុន)មានឈ្មោះ [redacted] លក្ខិណា, [redacted] សុផារី និងឈ្មោះ [redacted] សុខញ៉ [redacted] វិជ្ជរា)បានធ្វើការបែងចែកជាមួយសន្តតិជន(កូនក្រោយសហាចុងចម្លើយ)ឈ្មោះ [redacted] សុផារី( [redacted] សុផារី),ឈ្មោះ [redacted] សំអាង( [redacted] សំអាង)និងឈ្មោះ [redacted] សុភា (អ៊ុល សុភា)រួចហើយ តាមដីកាសម្រេចលេខ១២១ ពស.រវ "ក"/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប ដែលបានបែងចែកនេះគឺ៖

កូនមុន មានឈ្មោះ [redacted] លក្ខិណា, [redacted] សុផារី និងឈ្មោះ [redacted] សុខញ៉ [redacted] វិជ្ជរា)ទទួលបាន៥០% នៃចំណែកមតិករបស់ឈ្មោះ [redacted] សុខហូរ ( [redacted] សុខហូ)គឺស្មើ ២៥%នៃចំណែកមតិករួម ហើយទទួលបានចំណែកដីស្មើនិងទំហំ ៥,៥មX៤៨ម ផ្នែកខាងជើង។

កូនក្រោយ (សហាចុងចម្លើយ)មានឈ្មោះ [redacted] សុផារី( [redacted] សុផារី),ឈ្មោះ [redacted] សំអាង( [redacted] សំអាង) និងឈ្មោះ [redacted] សុភា [redacted] សុភា)ទទួលបាន៥០% នៃចំណែកមរតករបស់ឈ្មោះ [redacted] សុខហូរ( [redacted] សុខហូ)គឺស្មើ២៥% នៃចំណែកមតិករួម ទទួលបានចំណែកដីស្មើនិងទំហំ៥,៥មX៤៨ម ផ្នែកខាងត្បូង។

ដោយឡែកចំណែកមតិករបស់មតកជនឈ្មោះ [redacted] អុល ( [redacted] អុល)ចំនួន៥០% នៃដីខាងលើនៅផ្នែកខាងត្បូង ដែលមានចំណែករបស់សន្តតិជន៩នាក់មាន:

កូនមុន ជាសហដើមចោទ ៦នាក់មាន ឈ្មោះ [redacted] អាត, [redacted] សុទ្ធា, [redacted] អោក , [redacted] អំ, [redacted] អ៊ុច,ឈ្មោះ [redacted] សុទ្ធិន។

កូនក្រោយ ជាសហាចុងចម្លើយ ៣នាក់មានឈ្មោះ [redacted] សុផារី( [redacted] សុផារី), [redacted] សំអាង( [redacted] សំអាង) និងឈ្មោះ [redacted] សុភា( [redacted] សុភា)នៅមិនទាន់បានធ្វើការបែងចែកនៅឡើយ។

**ការទាមទារខាងលើដោយសំអាងទៅលើឯកសារ៖**

-សំបុត្រកំណើតរបស់ឈ្មោះ [redacted] អាត (ថតចម្លង ០១ច្បាប់)។

-សំបុត្រកំណើតរបស់ឈ្មោះ [redacted] សុទ្ធា (ថតចម្លង ០១ច្បាប់) ។

-សំបុត្រកំណើតរបស់ឈ្មោះ [redacted] អោក (ថតចម្លង ០១ច្បាប់) ។

-សំបុត្រកំណើតរបស់ឈ្មោះ [redacted] អំ (ថតចម្លង ០១ច្បាប់) ។

-សំបុត្រកំណើតរបស់ឈ្មោះ [redacted] អ៊ុច (ថតចម្លង ០១ច្បាប់) ។

សំបុត្រកំណើតរបស់ឈ្មោះ [redacted] សុទ្ធិន (ថតចម្លង ០១ច្បាប់) ។

**ភស្តុតាងរបស់សហចុងចម្លើយលើឯកសារៈ**

-ពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (ថតចម្លង ០១ច្បាប់)។

-ពាក្យសុំដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ (ថតចម្លង ០១ច្បាប់)។

-លិខិតបញ្ជាក់ប្រវត្តិដី ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ (ថតចម្លង ០១ច្បាប់)។

**សេចក្តីថ្លែងការណ៍តបរបស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយៈ** ខ្លួនមិនទទួលស្គាល់ការទាមទាររបស់សហដើមចោទទាំងស្រុង តាមមូលហេតុដូចខាងក្រោមៈ

-មតិកដែលជាកម្មវត្ថុបណ្តឹងតវ៉ានេះ ត្រូវបានសាលាដំបូងខេត្តសៀមរាបសម្រេចបែងចែកតាមរយៈដីកាសម្រេចលេខ: ១២១ ពស.រវ"ក"១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ និងបានប្រគល់ជូនសហចុងចម្លើយរួចរាល់ ហើយបានចូលស្តាពរយោងតាមលិខិតបញ្ជាក់ដីកាសម្រេចស្ថាពរលេខ: ៩៤/២០១៩ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ។

-ឈ្មោះ [redacted] អុល ដែលត្រូវជាឪពុកបានទទួលមរណភាព នៅឆ្នាំ១៩៩០ គិតមកទល់នឹងកាលបរិច្ឆេទដាក់ពាក្យបណ្តឹងតវ៉ា មានរយៈពេល២៩ឆ្នាំ។ហេតុនេះសហដើមចោទ ផ្លោះសិទ្ធិក្នុងការទាមទារ ដោយមូលហេតុ ផុតអាជ្ញាយុកាលនៃការទាមទារ។ សហដើមចោទ គ្មានសិទ្ធិទាមទារឡើយ ដោយច្បាប់កំណត់ត្រឹមតែ៥(ប្រាំ)ឆ្នាំប៉ុណ្ណោះ។

-សហដើមចោទពុំដែលបានតវ៉ា ឬទាមទារមតិកម្តងណាឡើយ។នៅពេលដែលឪពុកបានទទួលមរណភាពនៅឆ្នាំ១៩៩០ នៅភូមិដូនកែន ឃុំសំរោង ស្រុកសំរោង ខេត្តឧត្តរមានជ័យ សហដើមចោទទាំង៦នាក់ រួមទាំងម្តាយបង្កើតមិនបានមកចូលរួមធ្វើបុណ្យសព និងបុណ្យគំរប់ខួប១០០ថ្ងៃជូនឪពុកនោះទេ។ គឺមានតែសហចុងចម្លើយ និងម្តាយបង្កើតបានធ្វើដំណើរពីខេត្តសៀមរាប ដើម្បីធ្វើពិធីបុណ្យសព និងបុណ្យគំរប់ខួប១០០ថ្ងៃ តាមប្រពៃណីជូនឪពុក ដោយទទួលរ៉ាប់រងទាំងស្រុងនូវចំណាយសម្រាប់ពិធីបុណ្យ។

-មតិក ដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ានេះ គឺជាទ្រព្យដោយឡែករបស់ម្តាយសហចុងចម្លើយ ដែលបានទិញនៅឆ្នាំ១៩៨៨ ក្នុងតម្លៃ២ជីមាស ជាប្រាក់របស់គាត់សុទ្ធ

សាធ ព្រោះពេលនោះឪពុកទៅធ្វើជាទាហាន មិនមានពេលរកស៊ីចិញ្ចឹមគ្រួសារនោះទេ។

-សហដើមចោទ បានទទួលនូវចំណែកមតិករបស់ឈ្មោះ [redacted] អុល ដែលជាដីកេរនៅខេត្តកំពង់ធំ គ្រប់ៗគ្នាអស់ហើយ។ ប៉ុន្តែចុងចម្លើយមិនទាន់បានទទួលនូវចំនែកមតិករបស់ឈ្មោះ [redacted] អុល ដែលជាដីកេរ្តិ៍នៅខេត្តកំពង់ធំនោះឡើយ។

ស្ថានភាពគតិយុត្តិនៃការទាមទារ

-សហចុងចម្លើយ មានដីកាសម្រេចបែងចែកមតិកដែលបានចូលស្ថាពរ ហើយអាជ្ញាសាលាបានអនុវត្ត និងប្រគល់ចប់ស្ថាពរ។

-ការកែប្រែដីកាសម្រេចលេខៈ ១២១ ពស.រ"ក"/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១៩ របស់សាលាដំបូងខេត្តសៀមរាប ដោយហេតុផលមិនសមរម្យ ធ្វើឲ្យប៉ះពាល់ជាខ្លាំងដល់ស្ថេរភាពគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា។

-ការទាមទាររបស់សហដើមចោទគឺផុតអាជ្ញាយុកាលបាត់ទៅហើយ យោងតាមក្រមរដ្ឋប្បវេណី។

**សេចក្តីថ្លែងការណ៍មេធាវីតំណាងដោយអាណត្តិរបស់សហដើមចោទតបះ**

-មិនថាសាលក្រមរដ្ឋប្បវេណី ឬដីកាសម្រេចនោះទេ ឲ្យតែសម្រេចប៉ះពាល់សិទ្ធិតតិយជនអាចប្តឹងតវ៉ាបានតាមមាត្រា ៣៦៥ នៃក្រមនីតិរដ្ឋប្បវេណី ហេតុនេះហើយបានសហដើមចោទប្តឹងតវ៉ាមិនឲ្យអនុវត្តដីកាសម្រេចលេខៈ ១២១ ពស.រ"ក"១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប ។

-ចំពោះសហចុងចម្លើយលើកឡើងថាសហដើមចោទថ្លោះសិទ្ធិក្នុងការទាមទារមតិក ដោយសារមតកជនបានមរណភាពក្នុងឆ្នាំ១៩៩០ ហើយច្បាប់បានកំណត់ត្រឹមតែ៥(ប្រាំ)ឆ្នាំប៉ុណ្ណោះ គឺមិនត្រឹមត្រូវទេ បើតាមក្រមរដ្ឋប្បវេណី ឬក្រមនីតិវិធីរដ្ឋប្បវេណីគ្មានកំណត់អំពីអាជ្ញាយុកាលនៃការទាមទារមតិកនោះទេ។ មតិកកើតនៅក្រោយពេលមតកជនបានទទួលមរណភាព។ ចំពោះច្បាប់បានកំណត់អាជ្ញាយុកាលត្រឹមតែ៥(ប្រាំ)ឆ្នាំ គឺសំដៅលើឯកសារផ្សេងៗ។

-សហចុងចម្លើយលើកឡើងថាសហដើមចោទពុំដែលបានប្តឹងតវ៉ា ឬទាមទារមតិកម្តងណាឡើយនៅពេលដែលឪពុកឈ្មោះ [redacted] អុល ([redacted] អុល) បានទទួលមរណភាពនៅឆ្នាំ១៩៩០។ នេះជាសិទ្ធិរបស់សហដើមចោទព្រោះពួកគាត់យល់ពុំទាន់មានពេលគ្រប់គ្រាន់ ពុំសូវយល់ពីបញ្ហាផ្លូវច្បាប់ទើបមិនទាន់ប្តឹង។

-មតិក ដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ានេះ គឺជាទ្រព្យដោយឡែករបស់ម្តាយសហចុងចម្លើយ ដែលបានទិញនៅឆ្នាំ១៩៨៨ ក្នុងតម្លៃ២ជីមាស ជាប្រាក់របស់គាត់សុទ្ធសាធ ព្រោះពេលនោះឪពុកទៅធ្វើជាទាហាន មិនមានពេលរកស៊ីចិញ្ចឹមគ្រួសារនោះទេ។

-សហចុងចម្លើយបានលើកឡើងការទាមទារមត៌ករបស់សហដើមចោទ គឺជាទ្រព្យសម្បត្តិដោយឡែក ប៉ុន្តែតាមការពិតជាទ្រព្យសម្បត្តិរួមរវាងឈ្មោះ [redacted] អុល [redacted] អុល និងឈ្មោះ [redacted] សុខហួរ ដូចជាៈ ពាក្យស្នើសុំកាន់កាប់ប្រើប្រាស់ដីធ្លីឈ្មោះពីរនាក់ ,ទិញរួមគ្នានៅក្នុងពេលរួមរស់ជាមួយគ្នា,ក្នុងឯកសារបញ្ជាក់ថាឈ្មោះពីរនាក់,ក្នុងដីកាសម្រេចលេខៈ ១២១ ពស.រវ"ក"/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ ឈ្មោះពីរនាក់។

សរុបមកសហដើមចោទ និងសហចុងចម្លើយ គឺជាសន្តតិជនលំដាប់ទីមួយតាមមាត្រា ១១៥៦ នៃក្រមរដ្ឋប្បវេណី ដែលត្រូវបានទទួលចំណែកមត៌កពីមរកជនឈ្មោះ [redacted] សំរូល ស្មើៗគ្នា។ដូចនេះស្នើសុំតុលាការធ្វើការសម្រេចតាមការទាមទារដូចពាក្យបណ្តឹងតវ៉ា ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩។

## សំអាងហេតុ

១-តាមលទ្ធផលនៃការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងតាមសេចក្តីថ្លែងការណ៍មេធាវីតំណាងដោយអាណត្តិសហដើមចោទ ឃើញថាៈ

ក-សហដើមចោទ និងសហចុងចម្លើយពិតជាកូនបង្កើត ឬសន្តតិជនលំដាប់ទីមួយ របស់មតកជនឈ្មោះ [redacted] អុល ដែលមានមត៌កដីទំហំ១១,១១ម គុណ ៤៨ម ដែលស្ថិតនៅផ្នែកម្ខាងនៃក្បាលដីលេខៈ ១៦៥៥ មានព្រំប្រទល់ ខាងជើងទល់នឹងក្បាលដីលេខៈ ១៦៥៥, ខាងត្បូងទល់នឹងក្បាលដីលេខ ១៧០៦ ខាងកើតទល់នឹងក្បាលដីលេខ ១៥៧១ និងខាងលិចទល់នឹងផ្លូវបេតុង មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ពិតប្រាកដមែន។

ខ-តាមសេចក្តីថ្លែងការណ៍មេធាវីតំណាងដោយអាណត្តិចុងចម្លើយតបថាៈ ខ្លួនមិនទទួលស្គាល់ការទាមទាររបស់ដើមចោទគ្រប់ចំណុចទាំងអស់ ដោយហេតុថាៈ មត៌កដែលជាកម្មវត្ថុបណ្តឹងតវ៉ានេះ ត្រូវបានសាលាដំបូងខេត្តសៀមរាប សម្រេចបែងចែកតាមរយៈដីកាសម្រេចលេខៈ ១២១ ពស.រវ"ក"១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ និងបានប្រគល់ជូនសហចុងចម្លើយរួចរាល់ ហើយបានចូលស្ថាពរយោងតាមលិខិតបញ្ជាក់ដីកាសម្រេចស្ថាពរលេខៈ ៩៤/២០១៩ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ ផ្លោះសិទ្ធិក្នុងការទាមទារ ដោយមូលហេតុផុតអាជ្ញាយុកាលនៃការទាមទារសិទ្ធិទាមទារច្បាប់កំណត់ត្រឹមតែ៥(ប្រាំ)ឆ្នាំប៉ុណ្ណោះ។ មត៌កដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ានេះ គឺជាទ្រព្យដោយឡែករបស់ម្តាយសហចុងចម្លើយ។ តាមការពិនិត្យភស្តុតាងដីកាសម្រេចនេះ ឃើញថាមត៌កដីទំហំ១១,១១ម គុណ ៤៨ម ពិតជាទ្រព្យសម្បត្តិរបស់មតកជនឈ្មោះ [redacted] សំអុល។ ការអះអាងមេធាវីតំណាងដោយអាណត្តិចុងចម្លើយឈ្មោះ [redacted] សុធារី ថាសហដើមចោទផ្លោះសិទ្ធិក្នុងការទាមទារដោយសារផុតអាជ្ញាយុកាលច្បាប់កំណត់ត្រឹមតែ៥(ប្រាំ)ឆ្នាំ គឺមិនត្រឹមត្រូវទេ តាមមាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណី គឺមានន័យថាអំឡុងពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដីកាសម្រេចបែងចែកមត៌កបានចូល

ស្ថាពរ ហើយបើតាមដីកាសម្រេចលេខៈ ១២១ ពស.រវ "ក"/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ បានចូលស្ថាពរនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៩ បើគិតមកដល់ថ្ងៃដែលសហដើមចោទធ្វើការប្តឹងតវ៉ា នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ គឺមានន័យថារយៈពេល៥ (ប្រាំ)ឆ្នាំ មិនទាន់ផុតទេ ដូច្នេះសហដើមចោទនៅតែមានអត្ថិភាពនៃសិទ្ធិក្នុងការប្តឹងទាមទារមតិកដែលជាចំណែករបស់ខ្លួនបានស្របតាមមាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណី។

២-តាមសំអាងហេតុ ក,ខ ខាងលើ ឃើញថាការប្តឹងទាមទាររបស់សហដើមចោទ មានលក្ខណៈត្រឹមត្រូវ គប្បីតុលាការទទួលស្គាល់ការទាមទារតាមពាក្យបណ្តឹងតវ៉ា ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៩ របស់សហដើមចោទ។

៣-តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិសហដើមចោទលើកឡើងថា បើតាមក្រមរដ្ឋប្បវេណី ឬក្រមនីតិវិធីរដ្ឋប្បវេណី គ្មានកំណត់អំពីអាជ្ញាយុកាលនៃការទាមទារមតិកនោះទេ គឺផ្ទុយនឹងមាត្រា ១៣០៤ នៃក្រមរដ្ឋប្បវេណី ដែលចែងអំពីអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារឲ្យធ្វើបដិទានសន្តតិកម្ម។

៤-សហចុងចម្លើយឈ្មោះ [redacted] សំអាង ([redacted] សំអាង) និងឈ្មោះ [redacted] សុភា ([redacted] សុភា) មិនបានចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែបានទទួលដំណឹងត្រឹមត្រូវតាមនីតិវិធី ដូចនេះតុលាការអាចដំណើរការនីតិវិធីរបស់ខ្លួនបាន តាមមាត្រា ២៥២,២៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៥-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហដើមចោទ និងសហចុងចម្លើយ។

## សេចក្តីសម្រេចបញ្ចប់

១-មិនអនុញ្ញាតអនុវត្តដីកាសម្រេចលេខៈ ១២១ ពស.រវ "ក"/១៩ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៩ របស់សាលាដំបូងខេត្តសៀមរាប។

២-លុបចោលការអនុវត្តតាមកំណត់ហេតុអនុវត្ត ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៩ អាជ្ញាសាលានៃសាលាដំបូងខេត្តសៀមរាប ត្រង់ចំណុច១ ដែលមានខ្លឹមសារថា "ភាគីម្ចាស់បំណុលនៃការអនុវត្តមានឈ្មោះ [redacted] សុធារី,ឈ្មោះ [redacted] សំអាត និងឈ្មោះ [redacted] សុភា សម្រេចយកចំណែកA ។

៣-ទទួលស្គាល់សហដើមចោទ និងសហចុងចម្លើយ ជាសន្តតិជនរបស់មតកជនឈ្មោះ [redacted] អុល ([redacted] អុល)។

៤-បែងចែកមតិក ដីទំហំ១១,១១ម គុណ ៤៨ម ដែលស្ថិតនៅផ្នែកខាងនៃក្បាលដីលេខៈ ១៦៥៥ មានព្រំប្រទល់ ខាងជើងទល់នឹងក្បាលដីលេខៈ ១៦៥៥, ខាងត្បូងទល់នឹងក្បាលដីលេខ ១៧០៦ ខាងកើតទល់នឹងក្បាលដីលេខ ១៥៧១ និងខាងលិចទល់នឹងផ្លូវបេតុង មានទីតាំងស្ថិតនៅភូមិចុងកៅស៊ូ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប របស់មរតកជនឈ្មោះ [redacted] អុល ([redacted] អុល) ឲ្យសន្តតិជនជា ៩ ចំណែក



Scanned with CamScanner

ស្មើគ្នា មានឈ្មោះ [redacted] អាត,ឈ្មោះ [redacted] សុទ្ធា,ឈ្មោះ [redacted] អោក,ឈ្មោះ [redacted] អំ,ឈ្មោះ [redacted] អ៊ុច,ឈ្មោះ [redacted] សុទ្ធិន,ឈ្មោះ [redacted] សុធារី([redacted] សុធារី), ឈ្មោះ [redacted] សំអាង [redacted] សំអាង) និងឈ្មោះ [redacted] សុភា (អ៊ុល សុភា)។

៥-ឲ្យសហដើមចោទ និងសហចុងចម្លើយរួមគ្នាទទួលបន្ទុកប្រាក់ប្រដាប់ក្តី។

សាលក្រមនេះបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០។

ទុកសិទ្ធិអោយប្តឹងឧទ្ធរណ៍នឹងសាលក្រមនេះក្នុងអំឡុងពេល១ខែ គិតចាប់ពីថ្ងៃដែលទទួលបានការបញ្ជូននៃលិខិតសាលក្រមនេះ។

**ចៅក្រម**

**ហត្ថលេខា និងត្រា** [redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១២កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅសៀមរាប, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner